# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣❀៣៣

## កិច្ចព្រមព្រៀងការព្យួរកិច្ចសន្យាការងារ

ថ្ងៃច័ន្ទ ទី០៥ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង០១:០០នាទីរសៀល និងម៉ោង១៩:០០នាទីយប់នៅក្នុងរោងចក្រ ណាហ្គាភីស ខបភើរេសិន លីមីតធីត អាសយដ្ឋាន ផ្លូវជាតិលេខ០១ អាគារទី២ ភូមិព្រែកត្រែង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ បានបើកកិច្ចប្រជុំពិភាក្សាគ្នាមួយរវាងក្រុមហ៊ុន និងប្រធានក្រុម ព្រមទាំង តំណាងកម្មករនិយោជិតទាំងអស់។

### ១.សមាសភាពអ្នកចូលរួម

#### ក.ភាគីតំណាងអោយក្រុមហ៊ុន

១-លោក Cao You Gou (ប្រធានរោងចក្រ)

២-លោក ពិន ផល្លីន (ប្រធានរដ្ឋបាល)

#### ខ.ភាគីតំណាងកម្មករនិយោជិត

១-លោក សោម គឹមសាន ២-លោក សំ សាមី ៣-លោក សឿង ស៊ីនួន ៤-លោក រី គុលា ៥-លោក ភ្លឹង ហួន ៦-អ្នកស្រី យ៉ុង សម្បត្តិ ៧-លោក យុង សុខមឿន ៨-អ្នកស្រី ខឿន សុខហេង ៩-លោក នូ ចុនសារ៉ន ១០-អ្នកស្រី ជា ចន្ទី ១១-អ្នកស្រី សុំអ៊ុល សូនីតា។

### ២.ខ្លឹមសារអង្គប្រជុំ

សមាជិកអង្គប្រជុំទាំងមូលបានលើកឡើងអំពីបញ្ហាការព្យួរកាងារនៅរោងចក្រក្នុងរយៈពេល ០២ ខែ ដោយចាប់ពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយពុំសូវមានការបញ្ជាទិញ។

ឆ្លងតាមការពិភាក្សា និងយោងតាមការសម្របសម្រួលស្ម័គ្រចិត្តដោះស្រាយដោយផ្តល់ឲ្យភាគីនីមួយៗ មានលទ្ធភាពទទួលយកបាន និងបង្កលក្ខណៈដោះស្រាយតាមស្ថានភាពជាក់ស្តែងដោយទាំងតំណាងរោងចក្រ ក៏ដូចជាតំណាងកម្មករនិយោជិតបានព្រមព្រៀងគ្នាតាមវិធីដោះស្រាយដូចខាងក្រោមៈ

១.រោងចក្របានឯកភាពផ្តល់ជូនប្រាក់ឈ្នួលកម្មករនិយោជិតចំនួន២៥ដុល្លារអាមេរិកក្នុង១ខែកំឡុងពេល ព្យួរ ការងារ។

២.តំណាងរោងចក្រ ឯកភាពតាមសំណើររបស់តំណាងកម្មករ និងប្រធានក្រុមទាំងអស់ហើយនៅពេល ក្រោយភាគីកម្មករនិយោជិតឯកភាពត្រូវធ្វើតាមនិតិវិធីនៃកិច្ចចរចា និងគោរពតាមនិតិវិធីច្បាប់។

### ៣.លទ្ធផលអង្គប្រជុំ

ជាលទ្ធផល នៃការពិភាក្សាភាគី ទាំងពីរបានឯកភាពគ្នាដូចខាងក្រោម:

១.រោងចក្រចាប់ផ្តើមព្យួរការងារកម្មករនិយោជិត ចំនួន៥០០នាក់។ ចាប់ផ្តើមពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២ ដល់ថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០២៣។

២.រោងចក្រផ្តល់ប្រាក់ឈ្នួល២៥ដុល្លារអាមេរិកក្នុង១ខែ បើកជូនថ្ងៃទី១០ នៅខែបន្ទប់។

៣.ករណីដែររោងចក្រមានការងារធ្វើក្នុងកំឡុងពេលព្យួរនោះរោងចក្រនឹងជូនដំណឹងសល់កម្មករនិយោជិតចូលធ្វើការមុនពេលកំណត់។

អង្គប្រជុំបានចប់សព្វគ្រប់នៅម៉ោង ១៥:០០នាទីនាថ្ងៃដដែលនិង២០:០០យប់ថ្ងៃដដែល។ ក្រោមបរិយាកាសរីករាយ និងមនោសញ្ចេតនាជាភាតរភាព ដោយបានចុះហត្ថលេខាក្នុងកំណត់ហេតុទុកជាភស្តុតាងផងដែរ។

**៤.ភាគីតំណាងសហជីព និងតំណាងកម្មករនិយោជិត**

១-លោក សោម គឹមសាន ២-លោក សំ សាមី ៣-លោក សឿង ស៊ីនួន ៤-លោក រី គុលា

៥-លោក ភ្លឹង ហួន ៦-អ្នកស្រី យ៉ុង សម្បត្តិ ៧-លោក យុង សុខមឿន

៨-អ្នកស្រី ខឿន សុខហេង ៩-លោក នូ ចុនសារ៉ន ១០-អ្នកស្រី ជា ចន្ទី

១១-អ្នកស្រី សុំអ៊ុល សូនីតា

ថ្ងៃចន្ទ ១២កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

ធ្វើនៅ កណ្តាល ថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០២២

**ម្ចាស់សហគ្រាស**

Cao You Gou